# សិទ្ធិប្រហាក់ប្រហែល
# Related Rights

KHIM KIRI

# អ្វីទៅជាសិទ្ធិប្រហាក់ប្រហែល?

គឺជាសិទ្ធិដែលមានទៅលើស្នាដៃដូចខាងក្រោម៖

១. **ស្នាដៃសម្តែង**

២. **ស្នាដៃហ្វូណូក្រាម**

៣. **ផលិតកម្មវីដេអូ** និង

៤. **អង្គភាពផ្សាយ**

(ម ២ ចំណុច ណ)

# ១. សិទ្ធិអ្នកសម្តែង

អ្នកសម្តែងទទួលបាននូវសិទ្ធិផ្តាច់មុខ ឬ អនុញ្ញាតឲ្យអ្នកដ៏ទៃក្នុងការអនុវត្តសិទ្ធិដូចជាៈ (ម ៤១)

- ការផ្សាយតាមទូរផ្សាយ និងការផ្សាយជាសាធារណៈនូវការសម្តែងរបស់ខ្លួន
- ការថតបញ្ចូលជាហ្វូណូក្រាមនូវការសម្តែង ដែលមិនទាន់បានថតបញ្ចូលជាហ្វូណូក្រាម
- ការផលិតឡើងវិញនូវការសម្តែង ដែលបានថតបញ្ចូលជាហ្វូណូក្រាម

# ១. សិទ្ធិអ្នកសម្តែង (ត)

អ្នកសម្តែងទទួលបាននូវសិទ្ធិផ្តាច់មុខ ឬ អនុញ្ញាតឲ្យអ្នកដ៏ទៃក្នុងការអនុវត្តសិទ្ធិដូជា: (ម ៤១)

- ការចែកចាយជាសាធារណ: តាមរយៈការលក់ ឬផ្ទេរកម្មសិទ្ធិនូវហ្វូណូក្រាមច្បាប់ដើម
- ការដាក់ជួល ឬ ការឲ្យខ្ចីជាសាធារណ:នូវហ្វូណូក្រាមច្បាប់ដើម ឬច្បាប់ចម្លង ស្តីពីការសម្តែងនោះ

# ១. សិទ្ធិអ្នកសម្តែង (ត)

- **ចំណាំ:** ប្រសិនបើគ្មានកិច្ចព្រមព្រៀងផ្ទុយពីនេះទេ នោះអ្នកសម្តែងមានសិទ្ធិ
  - អនុញ្ញាចាក់ផ្សាយ តាមអង្គភាពទូរផ្សាយណាមួយ ប៉ុន្តែអង្គភាពទូរផ្សាយផ្សេងទៀត ពុំមានសិទ្ធិធ្វើការចាក់ផ្សាយនោះទេ
  - អនុញ្ញាចាក់ផ្សាយ តាមអង្គភាពទូរផ្សាយណាមួយ ប៉ុន្តែអង្គភាពទូរផ្សាយនោះ ពុំមានសិទ្ធិថតបញ្ចូលជាហ្វូណូក្រាមទេ

# ១. សិទ្ធិអ្នកសម្តែង (ត)

អ្នកសម្តែងទទួលបាននូវសិទ្ធិផ្តាច់មុខ ឬ អនុញ្ញាតឲ្យអ្នកដទៃក្នុងការអនុវត្តសិទ្ធិដូជា: (ម ៤២)

- ទោះជាមានការផ្ទេរសិទ្ធិបេតិកភ័ណ្ឌក៏ដោយ អ្នកសម្តែងនៅតែមានសិទ្ធិឲ្យគេសរសេរឈ្មោះរបស់ខ្លួនការសម្តែងផ្ទាល់ ឬដែលបានថតទុក លើកលែងតែក្នុងករណីដែលវិធីនៃការប្រើប្រាស់ការសម្តែងនោះ ពុំតម្រូវឲ្យមានការសរសេរឈ្មោះ

# ១. សិទ្ធិអ្នកសម្តែង (ត)

អ្នកសម្តែងទទួលបាននូវសិទ្ធិផ្តាច់មុខ ឬ អនុញ្ញាតឲ្យអ្នកដ៏ទៃក្នុងការអនុវត្តសិទ្ធិដូជា: (ម ៤២)

- ជាពិសេស អ្នកសម្តែងមានសិទ្ធិជំទាស់គ្រប់រូបភាពនៃការបំផ្លើស ការតាត់តខ្លឹមសារខ្លះ ឬកែប្រែខ្លឹមសារនៃការសម្តែង ដែលនាំឲ្យខូចកេរ្តិ៍ឈ្មោះអ្នកសម្តែង

# ១. សិទ្ធិអ្នកសម្តែង (ត)

អ្នកសម្តែងទទួលបាននូវសិទ្ធិផ្តាច់មុខ ឬ អនុញ្ញាតឲ្យអ្នកដទៃក្នុងការអនុវត្តសិទ្ធិដូជា: (ម ៤៣)

- អ្នកសម្តែង មិនអាចហាមឃាត់នូវការផលិតឡើងវិញ និងការផ្សាយជាសាធារណៈ ពីការសម្តែងរបស់ខ្លួនបានឡើយ ប្រសិនបើការសម្តែងនោះមានលក្ខណៈបន្ទាប់ បន្សំនៅក្នុងសាច់រឿងស្ទូលរបស់ឈុត ឬ ស្លាដៃ ឬ ឯកសារសោទទស្សន៍

# ២. សិទ្ធិនៃស្នាដៃហ្វូណូក្រាម

- ផលិតករហ្វូណូក្រាមមានសិទ្ធិផ្ដាច់មុខក្នុងការថត ឬ ការផលិតឡើងវិញ ឬការផ្សព្វផ្សាយជាសាធារណៈ នូវហ្វូណូក្រាមរបស់ខ្លួន (ម ៩៤)។
- គ្រប់បទម្រង់នៃការផលិតឡើងវិញ ការលក់ ការជួល ការប្ដូរ ឬការផ្សព្វផ្សាយជាសាធារណៈ ត្រូវមានការអនុញ្ញាតពីម្ចាស់ស្នាដៃ (ម ៩៥(១))។
- មានសិទ្ធិចែកចាយជាសាធារណៈតាមរយៈការលក់ ឬការផ្ទេរកម្មសិទ្ធិនូវច្បាប់ដើម ឬច្បាប់ចម្លង នៅក្នុងករណីដែលគាត់ពុំទាន់បានអនុញ្ញាតឲ្យបុគ្គលណាម្នាក់ធ្វើការចែកចាយ (ម ៩៥(២))។

# ៣. សិទ្ធិផលិតកវីដេអូ

អាចជារូបវន្តបុគ្គល ឬនីតិបុគ្គល ដែលផ្តួចផ្តើមគំនិតក្នុងការថតបញ្ចូលតាមបច្ចេកទេសផ្សាយនូវរូបភាពផ្សេងៗ ជាឈុតឆាកសម្តែង ដែលមាន ឬគ្មានសម្លេង (ម ៤៦(១))។

គ្រប់ការផលិតឡើងវិញនូវវីដេអូក្នុងគោលដៅសម្រាប់ ការផ្សព្វផ្សាយ ការលក់ ការដូរ ឬជួល ដាច់ខាតត្រូវមានការអនុញ្ញាតពីផលិតករនោះ (ម ៤៦(២))។

**ចំណាំ:** ការផ្ទេរសិទ្ធិផលិតករវីដេអូ មិនអាចធ្វើឡើងដាច់ដោយឡែកពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិអ្នកសម្តែង ដែលបានរួមសហការផលិតវីដេអូនោះឡើយ (ម ៤៦(៣))។

# ៤. សិទ្ធិនៃអង្គភាពទូរផ្សាយ

ស្ថានីយវិទ្យុ ទូរទស្សន៍ និងទូរទស្សន៍ខ្សែកាប មានសិទ្ធិផ្តាច់មុខក្នុងការធ្វើ ឬអនុញ្ញាតឲ្យមានការថតកម្មវិធី ការផ្សព្វផ្សាយ ការចាក់ផ្សាយឡើងវិញ ការផលិតឡើងវិញ ការចែកចាយ ឬការដាក់ជួល ជាលើកដំបូងនូវច្បាប់ចម្លងនៃកម្មវិធីទាំងនោះរបស់ខ្លួន (ម ៤៧(១))។

ត្រូវមានការអនុញ្ញាពីអង្គភាពទូរផ្សាយ នូវរាល់ការថតចម្លងនូវកម្មវិធីក្នុងគោលបំណងដើម្បីលក់ ជួល ប្តូរ ចាក់ផ្សាយ ឬផ្សព្វផ្សាយនៅកន្លែងណាមួយ (ម ៤៧(២))។

# ការកម្រិតសិទ្ធិប្រហាក់ប្រហែល

សកម្មភាពខាងក្រោម អាចអនុវត្តបានដោយពុំចាប់មានការអនុញ្ញាត និងពុំតម្រូវឲ្យមានការបង់កម្រៃនោះទេ៖

១. សេចក្ដីរាយការណ៍ពីបច្ចុប្បន្នភាព ដោយស្ថិតក្នុងលក្ខខណ្ឌជាការដកស្រង់ខ្លីៗ ពីការសម្ដែង ហ្វូណូក្រាម ឬពីក្នុងការផ្សាយរបស់ទូរផ្សាយ

២. ការថតចម្លង សម្រាប់ប្រើប្រាស់ក្នុងការស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ

៣. ការថតចម្លង សម្រាប់ការសិក្សា លើកលែងតែការសម្ដែង ឬហ្វូណូក្រាមទាំងនោះ ផលិតឡើងក្នុងគោលបំណងសម្រាប់តែការសិក្សា

# ការកម្រិតសិទ្ធិប្រហាក់ប្រហែល

៤. អាគតដ្ឋានដែលជាសម្រង់ខ្លីៗ ពីការសម្តែង ហ្វូណូក្រាម ឬកម្មវិធីចាក់ផ្សាយនៃបណ្តាញទូរផ្សាយ ដោយស្របតាមទម្លាប់ល្អ ដើម្បីប្រើបាស់ក្នុងគោលបំណងជាព័ត៌មាន

៥. ការប្រើប្រាស់នានា ដែលជាករណីលើកលែង ដោយអនុលោមតាមកិច្ចការពារនៃសិទ្ធិអ្នកនិពន្ធ

៦. ការចាប់យករូបភាព និងសម្លេង ដើម្បីធ្វើការផ្សាយបន្តទាំងស្រុង ឬភាគខ្លះ ដោយអង្គភាពទូរផ្សាយ ពីបច្ចុប្បន្នភាពនៃពិធីបុណ្យ កិច្ចប្រជុំ ឬព្រឹត្តិការណ៍ជាតិនានា ពីស្ថានីយដើមនៅក្នុងពេលតែមួយ

# ការការពារសិទ្ធិប្រហាក់ប្រហែល

**ចំណាំ: ចំពោះសិទ្ធិអ្នកសម្តែង និងអង្គភាពផ្សាយ**

មិនត្រូវយកមកអនុវត្តទេ នៅពេលដែលអ្នកសម្តែងអនុញ្ញាតឲ្យគេថតបញ្ចូលនូវការសម្តែងរបស់ខ្លួន ទៅក្នុងហ្វូណូក្រាមដែលមានរូបភាព ឬសោតទស្សន៍ (ម ៥១)។

មិនត្រូវយកមកអនុវត្តទេ ក្នុងករណីអង្គភាពផ្សាយណាមួយដែលធ្វើការថតចម្លង និងផលិតឡើងវិញដោយមធ្យោបាយផ្ទាល់ខ្លួន ដើម្បីធ្វើការចាក់ផ្សាយក្នុងកម្មវិធីផ្សាយរបស់ខ្លួនសម្រាប់ការផ្សាយពាណិជ្ជកម្ម (ម ៥២(១))។

# ការកម្រិតសិទ្ធិប្រហាក់ប្រហែល

**ចំណាំ: ចំពោះសិទ្ធិអ្នកសម្តែង និងអង្គភាពទូរផ្សាយ**

គ្រប់ការផលិតឡើងវិញ ឬច្បាប់ចម្លង ត្រូវបំផ្លាញចោលក្នុងរយៈពេល ៦ខែ បន្ទាប់ពីការផលិត លើកលែងតែក្នុងករណីដែលតម្រូវឲ្យមានការរក្សាទុកស្នាដៃចម្លងមួយច្បាប់សម្រាប់ជាឯកសារ (ម ៥៣(២))។

# រយៈពេលនៃការការពារ

រយៈពេលនៃការការពារសម្រាប់ស្នាដៃអ្នកសម្តែង គឺ៥០ឆ្នាំ គិតចាប់ពីដំណាច់ឆ្នាំប្រកតីទិននៃការថតបញ្ចូលក្នុងហ្វូណូក្រាម បើក្នុងករណីពុំបានថតការសម្តែងបញ្ចូលក្នុងហ្វូណូក្រាម គឺត្រូវគិតចាប់ពីដំណាច់ឆ្នាំប្រកតីទិនដែលការសម្តែងបានប្រព្រឹត្តទៅ (ម ៥៣(១))។

# រយៈពេលនៃការការពារ

រយៈពេលនៃការការពារសម្រាប់ផលិតករហ្វូណូក្រាម គឺ ៥០ឆ្នាំ គិតចាប់ពីបំណាច់ឆ្នាំប្រកតីទិនដែលបានបោះផ្សាយហ្វូណូក្រាម បើពុំបានបោះផ្សាយហ្វូណូក្រាម គឺត្រូវគិតចាប់ពីបំណាច់ឆ្នាំដែលបានថតសម្លេងបញ្ចូលក្នុងហ្វូណូក្រាមនោះ (ម ៥៣(២))។

# រយៈពេលនៃការការពារ

រយៈពេលនៃការការពារសម្រាប់កម្មវិធីផ្សាយរបស់អង្គភាពទូរផ្សាយ គឺ ៥០ឆ្នាំ ដែលត្រូវគិតចាប់ពីបំណាច់ឆ្នាំប្រក្រតីទិន ដែលកម្មវិធីនោះត្រូវបានចាក់ផ្សាយ (ម ៥៣(៣))។

# ចំណាំ

មិនខុសពីសិទ្ធិអ្នកនិពន្ធទេ    គឺមិនតម្រូវឲ្យមានការដាក់តម្កល់ចំពោះសិទ្ធិអ្នកសម្តែង ផលិតករ ហ្វូណូក្រាម និងអង្គភាពទូផ្សាយ (ម ៥៥)។

# សំណួរ ចម្លើយ